រាជធានីភ្នំពេញ ,ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

**សេចក្ដីសំរេចលេខ ២៦ សសរ**

**ស្ដីពីការផ្ទេរសិទ្ធិ**

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្ដទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ឯកឧត្ដមរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

**សំរេច**

**ប្រការ ១** : ផ្ទេរសិទ្ធិជូនឯកឧត្ដម **ស៊ុំ ម៉ានិត** រដ្ឋលេខាធិការនៃទីស្ដីការគណៈរដ្ឋមន្ត្រី ជារដ្ឋលេខាធិការស្ដីទី នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជំនួសឯកឧត្ដម **សូ ឃុន** ដែលត្រូវអញ្ជើញទៅ បំពេញបេសកកម្មនៅបរទេស ចាប់ពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦ រហូតដល់ឯកឧត្ដមបញ្ចប់បេសកកម្ម ។

**ប្រការ ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និងឯកឧត្ដម **ស៊ុំ ម៉ានិត** ត្រូវទទួលបន្ទុកអនុវត្ដសេចក្ដីសំរេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខា និង ចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្ដលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្ដម រណឫទ្ធិ** | **ហ៊ុន សែន** |